# ទំនាយនិមិត្តលក្ខណៈ

អស់លោកអ្នក សូមកត់សម្គាល់ទៅបុព្វហេតុដែលកើតមានដល់លោកណា អ្នកណា ឬដល់របស់ផ្សេងៗ ក្នុងកាលប្រផ្នូលហេតុកើតមានឡើង ដូចជាការយល់សប្តិ ញាក់ភ្នែក ឬសត្វជ្រុះហេតុផលផ្សេងៗពីប្រផ្នូល ហេតុនោះមានដូចតទៅ:

១- បើមានហេតុក្នុងថ្ងៃអាទិត្យ មិនបានឱ្យផលដល់អ្នកណា

២- ចន្ទ បានដល់ញាតិមិត្ត ឬបងប្អូន បើមិនជិតក៏ឆ្ងាយ

៣- អង្គារ មានដល់អ្នកជាឧបការបុគ្គល គឺមាតាបិតាទាំងសងខាង

៤- ពុធ មានចំពោះស្វាមី ភរិយា ពុំនោះដល់កូនចៅ ឬកូនប្រសា

៥- ព្រហស្បតិ៍ កើតមានចំពោះគ្រូបាអាចារ្យ ឬចាស់ព្រឹទ្ធាចារ្យ

៦- សុក្រ មានចំពោះសត្វដែលខ្លួនចិញ្ចឹមថែរក្សាសព្វកាល

៧- សៅរ៍ កើតមានចំពោះខ្លួនឯង ជាអ្នកបានឃើញបុព្វហេតុ ។

## មើលពេលអ៊ុតសក់ កាត់សក់

កាលណាចង់បានឱ្យខ្លួនជាទីស្រឡាញ់ពេញចិត្តអ្នកទាំងពួង គប្បីជ្រើសរកថ្ងៃដែលប្រកបទៅដោយសោភ័ណឫក្ស សម្រាប់ទាញអារម្មណ៍របស់អ្នកទាំងឡាយក្នុងការឃើញរូបដោយនេត្រាផងទាល ។

១- អ៊ុតថ្ងៃអាទិត្យ មានលំអជាទីគួរគេកោតសរសើរ

២- ច័ន្ទ មានសម្រស់អន់ថយ មានគេរិះគន់ច្រើន

៣- អង្គារ បានជាសុខសាន្ត មានគេកោតសរសើរច្រើន

៤- ពុធ មានមន្ទិលសៅហ្មង គេនិយាយដើមច្រើន

៥- ព្រហស្បតិ៍ បានលាភផលពីទីជិតឆ្ងាយ

៦- សុក្រ និងបានជាស្នេហ៍មុខកាត់ទាញអារម្មណ៍

៧- សៅរ៍ ច្រើនអាស្រូវកេរ្តិ៍ឈ្មោះ ច្រើនមានឈ្លោះប្រកែក

..................................

១- កាត់សក់ថ្ងៃអាទិត្យ មានសិរីជោគ បានក្បេមក្សាន្ត

២- ច័ន្ទ មានសិទ្ធិជោគ បានក្សេមក្សាន្ត

៣- អង្គារ៍ អាប់រាសី អាប់កិត្តិយសរលោះធន

៤- ពុធ អប្បលក្ខណ៍ វង់ភក្ត្រមានមន្ទិល

៥- ព្រហស្បតិ៍ ទេព្តារក្សា និងជួយទំនុកបម្រុង

៦- សុក្រ មានសុវត្ថិ ភោគទ្រព្យចំរើនជានិរន្តរ៍

៧- សៅរ៍ មានជោគរាសីប្រសើរ ថ្កើងបុណ្យស័ក្តិ

អធិប្បាយ ៖ កាត់សក់បុរាណនិយម បើសៅរ៍៩កើត ឬ៩រោច ជាគុណប្រសើរឈ្នះសត្រូវ បានជាទីនិយមដល់អ្នក ទាំងពួង និងជាមហានិយម គឺស្នេហ៍មុខយ៉ាងពិសេសមែនហោង ។

ហេតុនេះ ការកាត់សក់ គឺជាជោគមួយផ្នែកសម្រាប់ប្រមូលផ្ដុំនូវសោភ័ណភាព និងជាការរំលោះនូវសោភ័ណភាព បានផង សិរិសួស្ដីក៏ដូច្នោះដែរ កាលណាកាត់ឬអ៊ុតសមហេតុសមផល បានសោភ័ណបរិបូរណ៍ បានទទួលលទ្ធផលជាទីរីក រាយសប្បាយ រួមក្រុមគ្រួសារ កើតសោមនស្ស ស្វែងរកផលប្រយោជន៍បានប្រកបសមប្រាថ្នា កាលណាអ៊ុតឬកាត់ខុស ទំនងហេតុផល មានតែសេចក្ដីក្រវល់ក្រវាយស្ទាក់ស្ទើរចិត្តជាប់ ។

## ទំនាយហេតុពិត

អស់លោកអ្នកនាង កាលណាចង់ដឹងហេតុពិតពីរឿងវិវាទប្ដីងផ្ដល់ផ្សេងៗ បណ្ដាលជាក្ដីក្ដាំជាមួយនឹងគេ ដើម្បីឱ្យ បានដឹងរឿងនោះពិតជាយើងឈ្នះគេ ឬយើងត្រូវចាញ់គេ ដំបូងត្រូវយកអាយុរបស់ខ្លួនតាំងជា២ខ្ទង់ គឺលើ និងក្រោម ។

ខ្ទង់លើយក៤គុណ ខ្ទង់ក្រោមយក៥គុណ រួចហើយយកទៅចែកនឹង៧ទាំង២ខ្ទង់ បើខ្ទង់ខាងលើលើសចំនួនសេស ច្រើនជាងនោះ កំណត់សេចក្ដីថា អាត្មាប្រាកដជាឈ្នះមែនពិត ផ្ទុយទៅវិញបើចែកទៅហើយ ខាងក្រោមនៅសល់សេស ច្រើនជាង នោះជាការអស់សង្ឃឹមហើយ គឺចាញ់គេប្រាកដ ។

ឧទាហរណ៍ ៖ នាយ ធ អាយុ ៣០ឆ្នាំ កើតរឿងដោយគេចោទប្ដឹង នាយថាធ្វើការជាកំហុសធ្ងន់ នាយមិនសុខចិត្ត ប្ដឹងតវ៉ាចំណាំតបវិញ រឿងនោះក៏តបមួយអន្លើសិន ទើបមើលពីហេតុពិតដូច្នេះ ។

៣០ គុណ ៤ ខាងលើ

ចែកនិង៧ពេលនេះ នាយ ធ ឃើញសេស

៣០ គុណ ៥ ខាងក្រោម

ខ្ទង់លើបានសេស ១, ខ្ទង់ក្រោមបានសេស ៣ យ៉ាងនេះកំណត់នាយ ធ មានតែការចាញ់គេតប្រកែកបាន ។

.................................................